**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា

## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបិទ
## កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៥

ថ្ងៃពុធ ១៤រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩

ត្រូវនឹងថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងមានវត្តមានដ៏ឧត្តុង្គឧត្តមក្នុងកិច្ចប្រជុំនាពេលនេះ!**

ឆ្លងកាត់នូវការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹក កិច្ចប្រជុំពេញអង្គរបស់យើងបានធ្វើបទបង្ហាញ រួមនឹងការពិភាក្សា និងផ្តល់យោបល់យ៉ាងផុលផុស ដែលនាំឱ្យយើងទទួលបាននូវលទ្ធផលគួរជាទីមោទនៈសមស្របទៅនឹងកម្មវត្ថុនៃកិច្ចប្រជុំនាពេលនេះ ដែលខ្ញុំសូមសង្ខេបជូនដូចតទៅ ៖

- **ទី១-** ការអនុម័តជាគោលការណ៍នូវ សេចក្តីព្រាងវឌ្ឍនភាពនៃការអនុវត្តសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២៥។
- **ទី២-** ដាក់ចេញនូវសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៥។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**

ទោះបីជាយើងមានពេលវេលាតែមួយព្រឹកក៏ពិតមែន ប៉ុន្តែដោយការចូលរួមយ៉ាងសកម្មរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា បានធ្វើឱ្យកិច្ចប្រជុំដ៏មានតម្លៃរបស់យើងទទួលបានលទ្ធផលផ្លែផ្កាគួរជាទីមោទនៈ។ ខ្ញុំសូមឆ្លៀតយកឱកាសនេះ ថ្លែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្របំផុតជូនចំពោះសមាជិក សមាជិកានៃអង្គពិធីទាំងមូល។

ទន្ទឹមនឹងនេះ ដើម្បីឈានទៅសម្រេចបាននូវគោលដៅលុបបំបាត់ជំងឺអេដស៍ យើងត្រូវចាំបាច់អនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ឱ្យបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់។ យើងត្រូវបង្កើតបរិយាកាសអំណោយផលជាវិជ្ជមានបំផុត

ដើម្បីជួយសម្រួលការឆ្លើយតបឱ្យប្រព្រឹត្តទៅដោយរលូន ដោយដកចេញឱ្យអស់នូវរបាំងនានាដូចជាវិសមភាពសង្គម ការរើសអើងក្នុងការទទួលសេវាជាដើម ដើម្បីចូលរួមចំណែកពង្រឹងការឆ្លើយតបឱ្យបានទ្វេដង និងសូមអំពាវនាវឱ្យថ្នាក់ដឹកនាំគ្រប់ស្ថាប័នជាតិ វិស័យឯកជន ដៃគូអភិវឌ្ឍ សង្គម ស៊ីវិលអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋកម្ពុជាទាំងអស់ ចូលរួមយ៉ាងសកម្មតាមអភិក្រមនៃជវភាពនៃប្រព័ន្ធតួអង្គតែមួយ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍យកចិត្តទុកដាក់ខ្ពស់ក្នុងភាពជាម្ចាស់លើ ការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ ដោយធានាឱ្យបាននូវអត្រាគ្របដណ្តប់ទូទាំងប្រទេសទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងសហគមន៍។

ឆ្លៀតឱកាសមុនបិទកិច្ចប្រជុំពេញអង្គរបស់យើង ខ្ញុំសូមផ្តល់ជូននូវចំណាប់អារម្មណ៍បូកសរុបលទ្ធផលជារួមដែលទទួលបានពីកិច្ចប្រជុំនេះដូចខាងក្រោម៖

១- ជារួម យើងទាំងអស់គ្នាពិតជាបានខិតខំអនុវត្តផែនការសកម្មភាព សម្រាប់រយៈពេល៦ខែចុងឆ្នាំ២០២៥ ប្រកបដោយប្រសិទ្ធភាព។ ការអនុវត្តនេះបានកើតចេញពីការចូលរួមរបស់ក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ព្រមទាំងអង្គការសង្គមស៊ីវិល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

២- សូមកោតសរសើរចំពោះក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលបានប្រឹងប្រែងចូលរួមអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ ២០២៣-២០២៨ និងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៤-២០២៨។

៣- សូមវាយតម្លៃខ្ពស់ចំពោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានចូលរួមជំរុញឱ្យមាននូវវឌ្ឍនភាពក្នុងការអនុវត្តការងារឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ តាមរយៈការផ្តល់ថវិកា និងការរៀបចំនីតិវិធីប្រើប្រាស់កញ្ចប់ថវិកាជាតិដល់ក្រសួង ស្ថាប័ន និងរាជធានី ខេត្តទាំង២៥។

៤- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បន្តសហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីសិក្សាលើលទ្ធភាពផ្តល់និងប្រើប្រាស់អត្ថប្រយោជន៍គាំពារសង្គម ជាពិសេស មូលនិធិសមធម៌សុខាភិបាល ក្នុងការគាំទ្រដល់ការងារឆ្លើយតបនឹងការឆ្លងរាលដាលមេរោគអេដស៍ ដោយលើកទឹកចិត្តឱ្យប្រជាជនគន្លឹះស្ម័គ្រចិត្តមកធ្វើតេស្តឈាមរកមេរោគអេដស៍និងបង្កើនការមកទទួលយកសេវាសុខភាព។

៥- បន្តអន្តរាគមន៍ផ្តោតជាសំខាន់លើក្រុមប្រជាជនគន្លឹះ និងយុវជនវ័យ ដើម្បីបង្កើនចំណេះដឹងអំពីមេរោគអេដស៍ ក៏ដូចជាការទទួលបានសេវាបង្ការនិងការធ្វើតេស្តរកមេរោគអេដស៍ និងស្វែងរកវិធីថ្មីៗទៀតក្នុងការធ្វើការ ដើម្បីផ្តល់សេវាទាក់ទងនឹងមេរោគអេដស៍ដល់អ្នកដែលមិនទាន់បានទទួលអន្តរាគមន៍។

ជាមួយគ្នានេះផងដែរ ខ្ញុំសូមផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

១- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានភារកិច្ចប្រមូលផ្តុំនូវរាល់ជាតុចូល និងអនុសាសន៍ទាំងអស់ដែលបានអនុម័តជាគោលការណ៍ក្នុងកិច្ចប្រជុំនេះ។ ជាតុចូល និង អនុសាសន៍ទាំងនេះត្រូវយកទៅរៀបចំនិងកែសម្រួល ដើម្បីដាក់ចេញនូវគម្រោងផែនការសកម្មភាពនាពេលខាងមុខឱ្យមានប្រសិទ្ធភាពខ្ពស់។

២- បន្តជំរុញនិងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសង្គម និងបង្កើតបរិយាកាសអំណោយផលឱ្យក្រុមប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍បានទទួលសេវាមេរោគអេដស៍ សេវាសុខាភិបាល និងសេវាគាំទ្រផ្នែកច្បាប់និងសង្គមផ្សេងទៀតប្រកបដោយប្រសិទ្ធភាព។

៣- បន្តជំរុញការពង្រឹងប្រព័ន្ធជាតិ ក្នុងការឆ្លើយតបជាពហុវិស័យ ចំពោះការរីករាលដាលនៃមេរោគអេដស៍និងជំងឺអេដស៍ ឈានទៅសម្រេចឱ្យបានក្នុងពេលឆាប់ៗនូវចីរភាពនៃកម្មវិធីអេដស៍នៅកម្ពុជា។

៤- បង្កើនការអង្កេត តាមដាន នូវឥរិយាបទប្រឈមថ្មីៗដូចជា ការប្រើប្រាស់បណ្តាញសង្គម ដើម្បីស្វែងរកដៃគូរួមភេទ ក្រុមអ្នកប្រើគ្រឿងញៀននៅពេលរួមភេទ (Chemsex) ដែលមិនបានបង្ការពីការឆ្លងមេរោគអេដស៍។

៥- បង្កើនតំបន់គ្របដណ្តប់ កម្មវិធីលេបថ្នាំបង្ការជាមុនការប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍(ប្រិព, PrEP) ឱ្យបានទូលំទូលាយ និងឱ្យកាន់តែមានប្រសិទ្ធភាព។ បន្តផ្សព្វផ្សាយការយល់ដឹងពីសារៈសំខាន់នៃការប្រើប្រាស់សេវាប្រិព ដើម្បីទាក់ទាញអ្នកដែលមិនទាន់បានដឹងឱ្យមកទទួលយកសេវា ពិសេសលើក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ និងក្រុមអ្នកបម្រើសេវាកម្សាន្ត។

៦- បន្តកិច្ចសហប្រតិបត្តិការ និងការចូលរួមពីភាគីពាក់ព័ន្ធជាពហុវិស័យ ការផ្លាស់ប្តូរផ្នត់គំនិតពាក់ព័ន្ធក្នុងការអនុវត្តនគោលនយោបាយ ព្រមទាំងការស្វែងរកថវិកាឱ្យបានសមស្រប ដើម្បីជំរុញឱ្យកម្ពុជាយើងឈានទៅសម្រេចគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨តាមកាលកំណត់។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះបំផុតជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិនិងអន្តរជាតិទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គដ៏មានសារៈសំខាន់នេះ។

តាមរយៈការចូលរួមយ៉ាងសកម្ម ការផ្តល់នូវគំនិតយោបល់ល្អៗ ជាមួយនឹងការពិភាក្សា បាននាំឱ្យយើងទទួលបាននូវលទ្ធផលល្អប្រសើរ សម្រាប់យកទៅប្រើប្រាស់ក្នុងការកែលម្អការអនុវត្តការងារប្រយុទ្ធនឹងមេរោគអេដស៍និងជំងឺអេដស៍ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមមួយកម្រិតទៀត។ ខ្ញុំសូម

ថ្លែងនូវការកោតសរសើរផងដែរចំពោះ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានខិតខំរៀបចំកិច្ចប្រជុំពេញអង្គនេះ ឱ្យប្រព្រឹត្តទៅបានដោយរលូន និងសម្រេចបាននូវលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈនាពេលនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់នូវជ័យមង្គល មហាប្រសើរ សេចក្តីសុខ សេចក្តីចម្រើន ប្រាជ្ញាឈ្លាសវៃ ដើម្បីបន្តការកិច្ច រួមជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទទួលបានជោគជ័យថ្មីៗបន្ថែមទៀត និងសូមប្រកាសបិទ "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៥**" ចាប់ពីពេលនេះតទៅ។

សូមអរគុណ។